# សួនសាធារណៈនៃរាជធានីភ្នំពេញ

Phnom Penh Public Park

*បណ្ឌិត* **ឈឿន ម៉ុនឆា**

*មន្ត្រីខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យប្រធាន*

*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*រាជធានីភ្នំពេញជាមជ្ឈមណ្ឌល សន្តិសុខ នយោបាយ សេដ្ឋកិច្ច សម្បត្តិវប្បធម៌ និងការទូត។ នាប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសមានសុខសន្តិភាព នយោបាយឈ្នះ-ឈ្នះ និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច រាជធានីភ្នំពេញប្រែក្លាយយ៉ាងឆាប់រហ័ស ពីទីក្រុងដែលញាំញី និងខ្ទិចខ្ទាំដោយភ្លើងសង្គ្រាម មកជាទីក្រុងដែលមានសន្តិភាព រីកចម្រើន ទំនើបនិងស៊ីវិល័យ។ ជាមួយគ្នានេះដែរ កំណើនយានយន្ត និងការកកស្ទះ អាគារខ្ពស់ៗ អគារពាណិជ្ជកម្ម ផ្សារទំនើប និងលំនៅឋានបានរីកដូចផ្សិតនៅស្ទើរគ្រប់ទីកន្លែងក្នុងរាជធានីភ្នំពេញ[១]។*

*គ្រប់បណ្តាទីក្រុងនៃប្រទេសនានាលើសកលលោក សុទ្ធសឹងមានសួនសាធារណៈសម្រាប់លម្អទីក្រុង និងភាពទាក់ទាញនៃប្រទេសនោះ។ សួនច្បារទីក្រុងបានផ្តល់នូវទីកន្លែងជួបជុំ លម្ហែកម្សាន្ត និងហាត់ប្រាណដ៏ពេញនិយម ដើម្បីផ្តល់នូវសុខមាលភាពទីក្រុង។*

## ១. និយមន័យ

*ពាក្យ "**សួន**" តាមរយៈវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ **ជួន ណាត** ឱ្យនិយមន័យថា សួនជាទីដីឬទីធ្លាឬបរិវេណ ដែលមានដាំរុក្ខជាតិចំរុះ និងដើមឈើផ្សេងៗជាលម្អ។ សួនឧទ្យាន សួនមានដើមឈើទាបៗខ្លះ ខ្ពស់ៗខ្លះ ដោយជួរ ដោយសង្កាត់សម្រាប់ដើរលេងកម្សាន្តសប្បាយ[២]។ ពាក្យ "**សួន**" ត្រូវបាន*

---

[១] *ការផ្សព្វផ្សាយក្នុងផេក ហ្វេសញូ "រាជធានីភ្នំពេញ បច្ចុប្បន្នសម័យតេជោ" ខែសីហា ឆ្នាំ២០២៤។*

[២] *វចនានុក្រមខ្មែររបស់សម្តេចសង្ឃ **ជួន ណាត** ភ្នំពេញ ឆ្នាំ២០១៨។*

គេប្រើដើម្បីភ្ជាប់ជាមួយដូចជាៈ សួនកំសាន្ត សួនច្បារ សួនច្បារដំណាំ សួនរុក្ខវិទ្យា សួនវិទ្យាសាស្ត្រ សួនដំណាំជុំវិញផ្ទះ សួនឧទ្យាន សួនទារក សួនស័ក្តិ សួនសត្វ និងសួនច្បារសាធារណៈ។

រីឯពាក្យ "**សាធារណៈ**" មានន័យថា ដែលទូទៅ ដែលទុកជាកណ្តាល ដែលប្រើបានទាំងអស់គ្នា ដែលមិនចំពោះមួយៗ ដែលរាប់រយរាប់ពាន់ ដូចជាៈ ការសាធារណៈ ការដែលត្រូវធ្វើទាំងអស់គ្នា។ បង្គន់សាធារណៈ បង្គន់សម្រាប់សាធារណជន។ ផ្លូវសាធារណៈ ផ្លូវសម្រាប់ប្រជាជនទូទៅ។ របស់សាធារណៈ របស់ដែលត្រូវប្រើបានទាំងអស់គ្នា។ សាធារណប្រយោជន៍ ប្រយោជន៍សម្រាប់សាធារណជន សួនសាធារណៈជាដើម។

សួនសាធារណៈ សំដៅទីធ្លាបៃតងដែលជាកន្លែងរាប់ចាប់ពីសួនច្បារ ការដាំដើមឈើនៅតាមដងវិថី ទីធ្លាវាលស្មៅ ឬសួនឧទ្យាន។ល។ ទាំងនោះគឺសុទ្ធតែជាសមាសធាតុនៃប្រព័ន្ធអេកូឡូស៊ីទីក្រុង និងចូលរួមចំណែកដល់ការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព។ សម្រាប់ប្រទេសកម្ពុជា ទីធ្លាបៃតងបានកើតមានឡើងតាំងពីសម័យដើមមកម៉្លេះ ជាពិសេសនៅរាជធានីភ្នំពេញ មានសួនច្បារច្រើនជាងគេ ការដាំដើមឈើតាមដងវិថីធំៗព្រមទាំងមានការអភិវឌ្ឍនូវគម្រោងលំនៅដ្ឋានអមដោយទីធ្លាបៃតងជាច្រើន។ អញ្ចឹង តើទីធ្លាបៃតងឬសួនសាធារណៈមានអត្ថប្រយោជន៍អ្វីខ្លះសម្រាប់សុខមាលភាពទីក្រុង?

## ២. អត្ថប្រយោជន៍សួនសាធារណៈ

សួនសាធារណៈ ជាទីធ្លាបៃតងដែលគេចាប់អារម្មណ៍ខ្លាំងជាងគេគឺសួនច្បារក្នុងទីក្រុងជាផ្នែកមួយដែលអាចឱ្យសាធារណជនធ្វើលម្ហែកាយនាយពេលព្រឹកឬពេលល្ងាចឬពេលយប់ ដូចជាមានការលេងកីឡា ការរត់ហាត់ប្រាណ ការជិះកង់ សម្រាប់កុមាររត់លេងនិងស្រែកលេងតាមចិត្ត មនុស្សចាស់ដើរកម្សាន្ត ការជួបជុំទំនាក់ទំនងសង្គម ហើយជាពិសេស សួនច្បារបានជួយលើកសម្រស់ដល់ទីក្រុងបានមួយផ្នែកធំដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ និងការវិនិយោគ។ លើសពីនេះ សួនច្បារប្រៀបដូចជាកន្លែងមួយសម្រាប់បែងចែកការរស់នៅក្នុងទីក្រុង មានន័យថាសួនច្បារជាកន្លែងសម្រាប់ឱ្យយើងគេចចេញពី

ទីប្រជុំជនដ៏មមាញឹក សំឡេងយានយន្តរំខានច្រើន ហើយមកអង្គុយ ឬដើរជជែកគ្នា អមដោយទីធ្លាបៃតងដ៏ស្រស់ស្អាត និងមានគុណភាពបរិយាកាសល្អ អាចបន្ធូរអារម្មណ៍មួយផ្នែកបន្ទាប់បំពេញការងារនានា។

### ៣. បច្ចុប្បន្នភាពនៃរាជធានីភ្នំពេញ

ភ្នំពេញ គឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា និងជាមជ្ឈមណ្ឌលសន្តិសុខ នយោបាយ សេដ្ឋកិច្ច សម្បត្តិវប្បធម៌ និងការទូត។ រាជធានីភ្នំពេញ ជាមជ្ឈមណ្ឌលពាណិជ្ជកម្មដែលប្រមូលផ្តុំទៅដោយសំណង់អគារលំនៅដ្ឋាន សាលារៀន មន្ទីរពេទ្យ វត្តអារាម ទីផ្សារដោះដូរមុខទំនិញ លើមុខជំនួញដួញដូរទាំងក្នុងស្រុកនិងក្រៅស្រុក ក្នុងលំហូរសាច់ប្រាក់ជាអតិបរមា ដែលរួមបញ្ចូលទាំងសេដ្ឋកិច្ចទីផ្សារ សង្គមកិច្ច និងនយោបាយ ដែលនាំឱ្យទីក្រុងទាំងមូលក្លាយជាទីកន្លែងរស់នៅប្រកបដោយភាពសម្បូរបែប និងភាពមមាញឹកពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេសកំណើនប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ។

ក្នុងឆ្នាំ២០២៣ ប្រជាជននៅរាជធានីភ្នំពេញ កើនដល់ប្រមាណជាង២លាននាក់ ហើយទីក្រុងភ្នំពេញ ក៏បានពង្រីកខ្លួនជាបន្តបន្ទាប់រហូតមកដល់សព្វថ្ងៃនេះ មានទំហំផ្ទៃដីជិត៧០០គីឡូម៉ែត្រការ៉េ មានចំនួន១៤ខណ្ឌ និង១០៥សង្កាត់[៣]។

ចំពោះវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រដ្ឋបាលរាជធានីបានកសាង សង់ស្ពានអាកាស ផ្លូវក្រោមដី ស្ពានអាកាសថ្មើរជើង និងសួនច្បារជាច្រើនកន្លែង ដើម្បីកាត់បន្ថយភាពកកស្ទះ បង្កភាពងាយស្រួលដល់អ្នកធ្វើដំណើរ ក៏ដូចជាបង្កើនគុណភាពជីវិតដល់អ្នករស់នៅក្នុងរាជធានីភ្នំពេញ។

ជាមួយគ្នា រាជធានីភ្នំពេញក៏មានសួនឬទីធ្លាសាធារណៈសំខាន់ៗដូចជា៖

#### ៣.១. សួនវត្តភ្នំដូនពេញ

វត្តភ្នំ ជារមណីយដ្ឋានប្រវត្តិសាស្ត្រ និងជាទីសក្ការៈដ៏សំខាន់នៅរាជធានីភ្នំពេញ។ សួនដែលនៅជុំវិញវត្តភ្នំបង្កើតជាទេសភាពដ៏ខៀវស្រងាត់ ទោះបីជា

[៣] ការផ្សព្វផ្សាយក្នុងផេក ហ្វ្រេសញូ "រាជធានីភ្នំពេញ បច្ចុប្បន្នសម័យតេជោ" ខែសីហា ឆ្នាំ ២០២៤។

ភ្នំពេញជាកន្លែងអ៊ូអរយ៉ាងណាក្តី។ ផ្ទៃដីដែលមានស្មៅខ្ចី និងដើមឈើត្រឈឹងត្រឈៃនេះត្រូវបានគេប្រើដើម្បីរៀបចំការប្រគំតន្ត្រី និងកម្មវិធីផ្សេងៗ ហើយជារៀងរាល់ឆ្នាំ វត្តភ្នំគឺជាកន្លែងប្រមូលផ្តុំការកម្សាន្តនៅថ្ងៃចូលឆ្នាំ។ ជាពិសេសសួនកុមារវត្តភ្នំដែលបានជួសជុល កែលម្អយ៉ាងស្រស់ស្អាតបានទាក់ទាញប្រជាពលរដ្ឋពីបណ្តាខេត្តនាំកូនៗរបស់ខ្លួនទៅទស្សនាលេងកម្សាន្តយ៉ាងច្រើនកុះករក្នុងព្រះរាជពិធីបុណ្យអុំទូកនៅរាជធានីភ្នំពេញ ដោយម្នាក់ៗមានទឹកមុខសប្បាយរីករាយប្រកបដោយស្នាមញញឹម។

### ៣.២. សួនព្រះបរមរាជវាំង

ព្រះបរមរាជវាំងមានទីតាំងស្ថិតនៅកណ្តាលរាជធានីភ្នំពេញ ក្បែរចំណុចប្រសព្វនៃទន្លេធំទាំងបួនដែលគេហៅថាទន្លេចតុមុខ ដែលនេះគឺជាលក្ខណៈពិសេសនៃព្រះបរមរាជខ្មែរហើយក៏ជាបុព្វហេតុដែលគេ ប្រសិទ្ធនាមព្រះបរមរាជវាំងនេះថា ព្រះបរមរាជវាំងចតុមុខមង្គលផងដែរ។

សួនច្បារមុខព្រះបរមរាជវាំងមានទំហំ ១០ ៨៣៣ម៉ែត្រការ៉េ ស្ថិតក្នុងភូមិ១ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញរាជធានីភ្នំពេញ ត្រូវបានចុះបញ្ជីតាមបច្ចេកទេសសុរិយោដី និងច្បាប់ភូមិបាលដោយក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងកាន់កាប់ដោយក្រសួងព្រះបរមរាជវាំង ដោយមានការគ្រប់គ្រងពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទៅតាមច្បាប់ជាធរមាន[៤]។

សួនច្បារមុខព្រះបរមរាជវាំងបានក្លាយជាទីធ្លាសាធារណៈដ៏ស្រស់ត្រកាលអមដោយវាលស្មៅ និងសួនផ្កាគួរជាទីទាក់ទាញសម្រាប់ភ្ញៀវទេសចរណ៍ជាតិនិងអន្តរជាតិ។

### ៣.៣. សួនវិមានឯករាជ្យ

វិមានឯករាជរចនាឡើងដោយយកលំនាំរចនាបថសម័យអង្គរ និងមានទីតាំងស្ថិតនៅចំកណ្តាលនៃបេះដូងរបស់រាជធានីភ្នំពេញ។ កសាងក្នុងឆ្នាំ ១៩៥៨ ជាការប្រារព្ធនៃការទទួលឯករាជ្យពីបារាំង វិមានឯករាជ្យនេះ មានទីតាំងស្ថិតនៅចំកណ្តាលរង្វង់មូល

[៤] គេហទំព័ររបស់ក្រសួងព័ត៌មាន ចេញផ្សាយថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០២៤។

ចរាចរណ៍ដែលចំណុចប្រសព្វមហាវិថីព្រះនរោត្តម និងមហាវិថីព្រះសីហនុ។

សួនច្បារវិមានឯករាជ្យ ជាទីតាំងដ៏ពេញនិយមមួយសម្រាប់អ្នកហាត់ប្រាណដែលពលរដ្ឋជាច្រើននាំគ្នាដើររត់ លេងកីឡា នៅសួនវិមានឯករាជ្យខាងកើត។ ក្រៅពីហាត់ប្រាណ ប្រជាពលរដ្ឋខ្លះទៀតបានមកអង្គុយលេង និងផ្ដិតរូបភាពនៅទីនោះផងដែរ។

## ៣.៤. សួនច្បារមាត់ទន្លេ

សួនច្បារមាត់ទន្លេ គឺជាកន្លែងដែលមានប្រជាប្រិយភាពមួយនៅរាជធានីភ្នំពេញ។ នៅទីនោះភ្ញៀវទេសចរអាចគយគន់ទេសភាពព្រះបរមរាជវាំងចំណុចប្រសព្វនៃទន្លេទាំងបួន និងស្រូបយកខ្យល់ជំនោរដ៏បរិសុទ្ធដែលបក់តាមទន្លេ។ នាពេលព្រះអាទិត្យអស្ដង្គត ភ្ញៀវទេសចរអាចជិះទូកទស្សនាទីក្រុងភ្នំពេញដែលមានភ្លើងចម្រុះពណ៌ដ៏ស្រស់ស្អាតផងដែរ។សួនច្បារមាត់ទន្លេស្ថិតក្នុងសង្កាត់ជ័យជំនះ ខណ្ឌដូនពេញរាជធានីភ្នំពេញ។ សួនច្បារមាត់ទន្លេមានចម្ងាយប្រមាណ១,១គីឡូម៉ែត្រពីវត្តភ្នំដោយធ្វើដំណើរតាមផ្លូវបក្សីចាំក្រុងបន្ទាប់មកបត់ស្ដាំដៃតាមផ្លូវព្រះសីសុវត្ថិរហូតដល់ទីនោះ។

ពេលដើរតាមបណ្ដោយមាត់ទន្លេ អ្នកនឹងឃើញខណ្ឌផ្សេងៗនៃរាជធានីភ្នំពេញកាលពីសម័យមុន ហើយជាពិសេសគឺអាគារពីសម័យអាណានិគមបារាំងមួយចំនួនដូចជា ប៉ុស្តិ៍ប្រៃសណីយ៍ (ក្លឹបអ្នកកាសែតបរទេស) និងអាគារជាច្រើនទៀត។ នៅតាមមាត់ទន្លេគឺមានសភាពអ៊ូអរ និងសម្បូរទៅដោយបានីយដ្ឋាន ហាង និងភោជនីយដ្ឋាន។

ឧទ្យានតាមមាត់ទន្លេជាកន្លែងល្អបំផុតក្នុងការស្រូបយកខ្យល់អាកាសជាពិសេសនៅពេលថ្ងៃលិចដែលជាពេលសីតុណ្ហភាពចុះត្រជាក់។ អ្នកអាចមើលមនុស្សសម្រាកលំហែកាយ និងដើរកម្សាន្តពេលរសៀលនៅលើសួន។ សម្រាប់អ្នកដែលក្រោកពីព្រលឹម ពួកគាត់អាចទស្សនាព្រះអាទិត្យរះដ៏ស្រស់ស្អាតលើដងទន្លេនៅខាងមុខព្រះបរមរាជវាំង។

## ៣.៥. សួនច្បារមុខវត្តបុទុមវតី

សួនច្បារមុខវត្តបុទុមវតី ក្រៅពីទីកន្លែងសម្រាប់ការដើរហាត់ប្រាណ និងអង្គុយលេង ជារៀងរាល់ចុងសប្ដាហ៍ នៅ

*ប៉ែកខាងជើងសួនវប្បធម៌រាជធានីភ្នំពេញ មានការរៀបចំដាក់តាំងសៀវភៅឱ្យសាធារណជនអានដោយសេរី ដែលទីធ្លាសាធារណៈអមដោយដើមឈើនិងវាលស្មៅស្រស់ត្រកាលជាទីមនោរម្យ។*

**៤. ភាពចាំបាច់ក្នុងការបង្កើតសួនសាធារណៈក្នុងទីក្រុង**

*នៅក្នុងទីក្រុងចាំបាច់ណាស់ក្នុងការបង្កើតសួនសាធារណៈ ដែលជាទីធ្លាបៃតងដូចជា ការដាំដើមឈើនៅតាមដងផ្លូវ ប្រសិនបើយើងធ្វើដំណើរតាមដងមហាវិថីកម្ពុជាក្រោម មហាវិថីម៉ៅសេទុង មហាវិថីនរោត្តម មហាវិថីព្រះសីហនុ វិថីព្រះអង្គឌួង។ល។ យើងនឹងសម្គាល់ឃើញដើមឈើធំៗដែលបានដាំនៅអមសងខាងផ្លូវតាំងពីសម័យយូរលង់មក។ នៅតាមដងផ្លូវគឺជាកន្លែងដែលយានជំនិះដំណើរការ ហើយវានឹងបញ្ចេញនូវឧស្ម័នពុលលើបរិយាកាស ដូចនេះការដាំដើមឈើស្រស់បំព្រងនៅតាមផ្លូវ នោះគឺកាត់បន្ថយឧស្ម័នពុលផង ជាម្លប់ត្រជាក់សម្រាប់ធ្វើដំណើរផង និងជួយកាត់បន្ថយភាពស្ត្រេសទៀតផង[៥]។*

*យោងតាមអង្គការសុខភាពពិភពលោក បានបង្ហាញថា ទីធ្លាបៃតងមានសារៈសំខាន់ខ្លាំងណាស់ក្នុងការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព។ ជាក់ស្តែងដើមឈើមានតួនាទីសម្រាប់កាត់បន្ថយសំឡេងរំខានទីក្រុង ជួយផលិតនូវអុកស៊ីហ្សែនសម្រាប់មនុស្ស ជួយកាត់បន្ថយបរិយាកាសពុល ជួយផ្តល់សំណើមនៅពេលព្រឹក កាត់បន្ថយកម្តៅទីក្រុង។ល។ ម្យ៉ាងវិញទៀត តាមការស្រាវជ្រាវថ្មីៗនេះបង្ហាញថា ទីក្រុងដែលមានសួនច្បារសម្រាប់ប្រជាជនធ្វើលំហាត់ប្រាណ បានធ្វើឱ្យអាយុសង្ឃឹមរស់កើនឡើងដល់ ៣,៣% ខ្ពស់ជាងទីក្រុងដែលគ្មានសួនធ្វើលំហាត់ប្រាណ ព្រោះជួយបង្កើននូវសុខមាលភាពនៃការរស់នៅ កាត់បន្ថយភាពតានតឹងស្ត្រេស បន្សុទ្ធបរិយាកាស សូម្បីទីធ្លាពណ៌បៃតងក៏ល្អដល់ភ្នែកសម្រាប់សម្លឹងមើលផងដែរ។*

**៥. ការបង្កើតសួនសាធារណៈនៅក្នុងរាជធានីភ្នំពេញ**

*បើទោះជារាជធានីភ្នំពេញមានសួនសាធារណៈមួយចំនួនសម្រាប់ការលើកកម្ពស់សុខមាលភាពទីក្រុងក៏*

[៥] *របាយការណ៍អចលនទ្រព្យកម្ពុជា "អត្ថប្រយោជន៍ទីធ្លាបៃតងសម្រាប់ទីក្រុង" ភ្នំពេញ ឆ្នាំ២០១៨។*

ដោយ ក៏រាជធានីភ្នំពេញនៅតែមានការខ្វះខាតសួនឧទ្យានសម្រាប់សាធារណជនទូទៅ ជាពិសេស សួនឧទ្យានសម្រាប់ប្រជាសហគមន៍នៅជុំវិញទីក្រុងដើម្បីប្រើប្រាស់បានដោយងាយស្រួល និងទទួលបានអត្ថប្រយោជន៍ផ្សេងៗទៀត[៦]។

ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈសាលារាជធានីភ្នំពេញ គ្រោងបង្កើតសួនសាធារណៈដ៏ធំមួយ ដែលមានទំហំប្រមាណ ៧០ហិកតា នៅភូមិសាស្ត្រទំនប់កប់ស្រូវ ដើម្បីជាកន្លែងហាត់ប្រាណ និងទីសម្រាកកម្សាន្តរបស់ពលរដ្ឋ។

ការបង្កើតនិងការដាក់បញ្ចូលសួនសាធារណៈខ្នាតតូច និងខ្នាតធំក្នុងរាជធានីភ្នំពេញបន្ថែមទៀត ជាពិសេសសម្រាប់សហគមន៍ដែលរស់នៅជុំវិញទីក្រុងក្នុងការអាចទទួលបានអារម្មណ៍សុវត្ថិភាព និងអត្ថប្រយោជន៍នានានៅពេលដែលបានបង្កើតទីធ្លាសាធារណៈឱ្យបានកាន់តែច្រើន។

ទីតាំងដែលត្រូវបានចាត់ទុកជាដីសាធារណៈគួរតែត្រូវបានផ្តល់អាទិភាពសម្រាប់ការផ្លាស់ប្តូរ។ តំបន់ដែលស្ថិតនៅក្រោមស្ពានអាកាសជាទូទៅ គឺជាទីធ្លាទំនេរទុកចោល ផ្លូវលំ និងតំបន់ដែលនៅជាប់នឹងប្រឡាយក៏គួរតែត្រូវបានកំណត់គោលដៅសម្រាប់បង្កើតសួនសាធារណៈផងដែរ។

## សន្និដ្ឋាននិងអនុសាសន៍

សួនឧទ្យាន រុក្ខជាតិបៃតង និងភាពស្រស់បំព្រងក្នុងទីក្រុង ពិតជាមានសារៈសំខាន់ណាស់ ព្រោះផ្តល់នូវបរិយាកាសសុវត្ថិភាពសម្រាប់ការរស់នៅ ដែលអាចឱ្យយើងសម្របខ្លួន មានសកម្មភាពច្នៃប្រឌិត និងជំរុញសកម្មភាពផ្សេងៗបន្ថែមទៀត ហើយប្រជាសហគមន៍ក៏អាចទទួលបានប្រយោជន៍ដល់សុខភាពពីទីធ្លាសាធារណៈបានយ៉ាងប្រសើរ។

ការបង្កើតសួនសាធារណៈបានដើរតួនាទីក្នុងការបង្កើតសុខសុវត្ថិភាពដែលលើកកម្ពស់មុខមាត់ទីក្រុង និងគាំពារសុខុមាលភាពប្រជាពលរដ្ឋ ព្រមទាំងបានផ្តល់ផលវិជ្ជមានសម្រាប់បរិស្ថាន

[៦] អង្គការសមាគមជាងត្នោត "សួនសាធារណៈនៅទីក្រុង ជាកន្លែងមួយដែលផ្សារភ្ជាប់ទំនាក់ទំនងមនុស្សក្នុងសង្គម" ខែកញ្ញា ឆ្នាំ២០២៤។

ផង កាត់បន្ថយឥទ្ធិពលកម្តៅផង កាត់បន្ថយទឹកជំនន់ផង និងកាត់បន្ថយការបំពុលខ្យល់ និងការបំពុលដោយសំឡេងទៀតផង។

យើងត្រូវកែប្រែ និងរៀបចំសួនសាធារណៈបែបណាឱ្យត្រូវទៅតាមតម្រូវការ និងអត្ថប្រយោជន៍ចាំបាច់របស់ប្រជាជននាសម័យកាលបច្ចុប្បន្ន។ សួនសាធារណៈនីមួយៗបានគ្របដណ្តប់លើផ្ទៃដីមួយផ្នែកនៃទីក្រុង ចឹងហើយបើសិនជាសួនទាំងនោះផ្តល់ប្រយោជន៍មកវិញដោយគ្រាន់តែជាគ្រឿងលម្អ ម្លប់បន្តិចបន្តួច មិនអាចប្រើប្រាស់នៅពេលថ្ងៃ មិនសូវមានកន្លែងជ្រក និងទីធ្លារៀបដោយការ៉ូឡាដែលជះកម្តៅ? តើវាស័ក្តិសម ឬស្មើតម្លៃគ្នានឹងផ្ទៃដីដែលសួនទាំងនោះបង្កើតឡើងដែរទេ?

សួនសាធារណៈគួរមានការកែប្រែដែលផ្តល់នូវមុខងារ និងលទ្ធភាពច្រើនជាងលំហសួន ដាំដើមឈើលម្អ ហើយប្តូរមកជាសួនសាធារណៈបែតងដ៏ពិតប្រាកដដែលប្រជាជនគ្រប់វ័យ គ្រប់វណ្ណៈ គ្រប់ពេលមិនថាអ្នកធ្វើការយប់ដើរលេងថ្ងៃ ឬអ្នកធ្វើការថ្ងៃ ដើរលេងយប់ សុទ្ធតែអាចចាកចេញពីភាពស្មុគស្មាញនៃជីវិតទីក្រុងដ៏មមាញឹក លម្ហែអារម្មណ៍ ប្រជុំគំនិត ព្យាបាលសុខភាព និងផ្លូវចិត្តនៅទីនោះបានគ្រប់ៗគ្នា។

រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងសាងសង់ព្រលានយន្តហោះថ្មី ហើយអាកាសយានដ្ឋានអន្តរជាតិភ្នំពេញនឹងធ្វើការផ្លាស់ប្តូរទៅកាន់អាកាសយានដ្ឋានអន្តរជាតិតេជោតាខ្មៅ ដែលមានទីតាំងស្ថិតនៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ ជាអនុសាសន៍ រាជរដ្ឋាភិបាលគួរតែះ

១) យកទីតាំងព្រលានយន្តហោះអន្តរជាតិភ្នំពេញ បង្កើតជាសួនឧទ្យានជាតិដ៏ធំមួយស្ថិតនៅកណ្តាលប៉ែកខាងលិចនៃរាជធានីភ្នំពេញ។

២) ដាំដុះដើមឈើធំៗនិងផ្កានៅតាមបណ្តោយផ្លូវយន្តហោះឱ្យមានម្លប់ត្រឈឹងត្រឈៃ នៅពេលប្រជាពលរដ្ឋចូលទៅកម្សាន្តប្រៀបដូចកំពុងស្ថិតនៅក្នុងព្រៃឈើដ៏ធំមួយក្នុងទីក្រុង។

៣) កែច្នៃអគារព្រលានយន្តហោះអន្តរជាតិភ្នំពេញសម្រាប់បង្កើតជាសារមន្ទីរបច្ចេកវិទ្យាជាតិ និងអគារពាណិជ្ជកម្មទំនើប។

៤) អភិរក្សនិងអភិវឌ្ឍទីតាំងប្រវត្តិសាស្ត្រសម្រាប់ជាសាធារណប្រយោជន៍។

៥) ទាក់ទាញភ្ញៀវទេសចរណ៍និងការវិនិយោគបរទេសបន្ថែមទៀត។

មួយវិញទៀត ទីលានចាក់សំរាមដង្កោ ស្ថិតនៅប៉ែកខាងត្បូងរាជធានីភ្នំពេញ ដែលជាកន្លែងចាក់សំរាមដ៏ធំនៃរាជធានីភ្នំពេញ។ រាជរដ្ឋាភិបាលគួរពិនិត្យលទ្ធភាពអនុញ្ញាតឱ្យក្រុមហ៊ុនបរទេសដែលមានសមត្ថភាពបច្ចេកវិទ្យាទំនើបធ្វើការកែច្នៃសំរាម ហើយប្រែក្លាយទីលានសំរាមដង្កោ ទៅជាសួនច្បារបៃតងដ៏ស្រស់បំព្រង។

ដូចនេះការបង្កើតសួនឧទ្យាននៅក្នុងរាជធានីភ្នំពេញបន្ថែម ជាប្រការចាំបាច់ ជាកន្លែងមួយដែលផ្សារភ្ជាប់ទំនាក់ទំនងមនុស្សក្នុងសង្គម ការគាំពារបរិស្ថាន លើកកម្ពស់សុខមាលភាពទីក្រុង និងទាក់ទាញអ្នកវិនិយោគបរទេស ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព៕

## ឯកសារយោង


១) ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ "**ប្រកាសឱ្យប្រើប្រាស់ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**"។

២) ព្រះរាជក្រឹត្យលេខ នស/រកត/០២២១/១១៥ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ ស្ដីពី "**តែងតាំងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ**"។

៣) អនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ "**ស្ដីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**"។

៤) រាជរដ្ឋាភិបាល គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ "**សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍រាជធានី**" រាជធានីភ្នំពេញ ខែមីនា ឆ្នាំ២០១៧។

៥) ក្រសួងបរិស្ថាន និងរដ្ឋបាលរាជធានីភ្នំពេញ "**ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០**" ឆ្នាំ២០១៩។

៦) ឋា ចាន់ធី "**ប្រវត្តិរាជធានីភ្នំពេញ បេះដូងនៃព្រះរាជាណាចក្រកម្ពុជា**" ឆ្នាំ២០២២។

៧) គេហទំព័រផ្លូវការហ្វេសប៊ុក "**រាជធានីភ្នំពេញ បច្ចុប្បន្នសម័យតេជោ**" រាជធានីភ្នំពេញ ឆ្នាំ២០២៦។

## ឧបសម្ព័ន្ធ






*ទិដ្ឋភាពវត្តភ្នំ ដែលជារមណីយដ្ឋានប្រវត្តិសាស្ត្រនៃរាជធានីភ្នំពេញ។*



វិមានឯករាជ្យរាជធានីភ្នំពេញជាមួយសួនច្បារនៅប៉ែកខាងកើត ឆ្ពោះទៅកាន់មាត់ទន្លេ។




ទីធ្លាសាធារណៈអមជាមួយសួនស្មៅសម្រាប់ប្រជាពលរដ្ឋដើរកម្សាន្តនិងហាត់ប្រាណ
នាពេលព្រឹក និងពេលល្ងាច។



*សួនច្បារនៅមាត់ទន្លេ និងទីធ្លាសាធារណៈសម្រាប់សម្រាកលំហែ និងដើរហាត់ប្រាណ នាពេលព្រឹក និងពេលល្ងាច។*



*ទិដ្ឋភាពដើមឈើនៅតាមបណ្តោយមហាវិថីព្រះនរោត្តម ឆ្ពោះទៅកាន់វិមានឯករាជ្យ នៅរាជធានីភ្នំពេញ នាទសវត្សឆ្នាំ១៩៦០។*



*ទិដ្ឋភាពនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដែលរាជរដ្ឋាភិបាលគួរពិនិត្យលទ្ធភាព បង្កើតជាសួនឧទ្យានសាធារណៈដ៏ធំមួយ ដើម្បីអភិរក្សនិងអភិវឌ្ឍសម្រាប់ផ្តល់នូវ សុខមាលភាពទីក្រុងនិងការទាក់ទាញអ្នកវិនិយោគបរទេសបន្ថែមៗ*





*ទីលានចាក់សំរាមដង្កោ រាជរដ្ឋាភិបាលពិនិត្យលទ្ធភាពឱ្យក្រុមហ៊ុនឯកជនដែលមាន ជំនាញកែច្នៃខ្ពស់ ដើម្បីអភិវឌ្ឍទីលាននេះឱ្យក្លាយជាសួនសាធារណៈដ៏ទាក់ទាញដល់ វិស័យទេសចរណ៍ សុខមាលភាពទីក្រុង និងការអភិវឌ្ឍប្រកបដោយចីរភាព៕*

